# JV-050-INFO CM តើមានអ្វីកើតឡើង បើកូនរបស់អ្នកត្រូវបានយកចេញពីផ្ទះរបស់អ្នក?

## តើហេតុអ្វីបានជាកូនរបស់ខ្ញុំ ត្រូវបានយកចេញពីខ្ញុំ?

មានគេបានរាយការណ៍ អំពីសុវត្ថិភាពនៃកូនរបស់អ្នក។ ដើម្បីការពារកូនរបស់អ្នក មន្ត្រីនគរបាល ឬអ្នកធ្វើការសង្គមកិច្ចបាន:

- យកកូនរបស់អ្នក ចេញពីផ្ទះរបស់អ្នក, និង
- បានស្នើតុលាការឲ្យចូលប្រឡូកក្នុងករណីនេះ ដើម្បីការពារកូនរបស់អ្នក។

## តើកូនរបស់ខ្ញុំនៅឯណាឥឡូវនេះ?

កូនរបស់អ្នក អាចនឹងនៅឯផ្ទះចិញ្ចឹមកូនជាបណ្តោះអាសន្ន ឬនៅឯទីជំរកនៅក្នុងខោនធីនេះ។ ដើម្បីឲ្យដឹងថែមទៀតអំពីអ្វីៗដែលកំពុងកើតឡើងចំពោះកូនរបស់អ្នក សំរាប់ករណីនេះ សូមទូរស័ព្ទទៅអ្នកធ្វើការសង្គមកិច្ច:

អ្នកធ្វើការសង្គមកិច្ច:

ទូរស័ព្ទ:

អ៊ី-មេល:

## តើកូនរបស់ខ្ញុំ នឹងត្រឡប់មកនៅជាមួយខ្ញុំ ឆាប់ៗប៉ុណ្ណា?

វាអាស្រ័យលើសភាពការណ៍។ អ្នកធ្វើការសង្គមកិច្ច នឹងពិនិត្យមើលស្ថានភាពនៅផ្ទះរបស់អ្នកឡើងវិញ និងសំរេចពីរបៀបល្អជំផុត ដើម្បីរក្សាកូនរបស់អ្នកដោយសុវត្ថិភាព។បើកូនរបស់អ្នកមិនត្រឡប់មកផ្ទះវិញ នៅមុនពេលអ្នកទៅតុលាការ កូនរបស់អ្នកអាចនឹងបានបញ្ជូនទៅ នៅជាបណ្តោះអាសន្នជាមួយនឹង:

- មាតាបិតាស្របច្បាប់ផ្សេងទៀតរបស់ក្មេង (បើអ្នកមិនរស់នៅជុំគ្នា),
- ញាតិសន្តាន ឬសមាជិកគ្រួសារជាប់សាលោហិត, ឬ
- មាតាបិតាចិញ្ចឹម។

## តើខ្ញុំមានសិទ្ធិ ដើម្បីព្យាយាមយកកូនរបស់ខ្ញុំមកវិញ ឬទេ?

មាន។ អ្នកមានសិទ្ធិដើម្បី :

- មានមេធាវីម្នាក់។ (តុលាការនឹងផ្តល់មេធាវីម្នាក់សំរាប់អ្នក បើអ្នកមិនអាចលៃលកបាន)។
- ចូលរួមក្នុងសវនាការនៅតុលាការទាំងអស់ អំពីកូនរបស់អ្នក។
- មានអ្នកបកប្រែក្នុងតុលាការ បើអ្នកមិនចេះនិយាយភាសាអង់គ្លេសបានល្អ។
- បដិសេធឆ្លើយសំណួរទាំងពួង ដែលអាចនឹងនាំឲ្យជាប់ចោទបទឧក្រិដ្ឋកម្ម ប្រឆាំងនឹងអ្នក។
- ប្រាប់មេធាវីរបស់អ្នក បើអ្នកមានសំណួរអំពីសិទ្ធិរបស់អ្នក ឬអំពីអ្វីៗដែលកើតឡើងនៅក្នុងតុលាការ។

## តើកូនរបស់ខ្ញុំមានសិទ្ធិ ដែរឬទេ?

មាន។ កូនរបស់អ្នកមានសិទ្ធិដូចអ្នកដែរ។ កូនរបស់អ្នកនឹងមានមេធាវីខុសពីអ្នក ដែលនឹង:

- ប្រាប់តុលាការពីអ្វីៗដែលក្មេងចង់បាន, និង
- ស្នើតុលាការឲ្យធ្វើអ្វីដែលល្អបំផុតសំរាប់ក្មេង។

## តើកូនរបស់ខ្ញុំ អាចដាក់ឲ្យនៅជាមួយញាតិសន្តាន បានឬទេ?

បាន។ អ្នកត្រូវតែប្រាប់ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកធ្វើការសង្គមកិច្ច នូវមាតាបិតាស្របច្បាប់ផ្សេងទៀត ព្រមទាំងញាតិសន្តានរបស់ក្មេង ដែលអាចមើលថែទាំកូនរបស់អ្នកបាន។ អ្នកធ្វើការសង្គមកិច្ចនឹងទាក់ទងគេ ដើម្បីសាកសួរបើសិនផ្ទះរបស់គេអាចទទួលយកក្មេងបាន និងមានសុវត្ថិភាពសំរាប់កូនរបស់អ្នក។

## តើខ្ញុំនឹងដឹងពេលវេលាទៅតុលាការ ដោយដូចម្តេច?

អ្នកនឹងទទួល*លិខិតជូនដំណឹង* មួយច្បាប់ ដែលប្រាប់ពេលវេលា ខែថ្ងៃឆ្នាំ និងទីកន្លែងធ្វើសវនាការនៅតុលាការ ។

***សារៈសំខាន់!*** តុលាការ និងអ្នកធ្វើការសង្គមកិច្ច នឹងផ្ញើឯកសារសំខាន់ៗជាច្រើនទៅឲ្យអ្នក។ បើអាសយដ្ឋានផ្ញើសំបុត្ររបស់អ្នកផ្លាស់ប្តូរ ត្រូវប្រញាប់ប្រាប់អ្នកធ្វើការសង្គមកិច្ចរបស់អ្នក។

## អ្វីៗដែលត្រូវរំពឹង

1. បន្ទាប់ពីកូនរបស់អ្នកត្រូវបានយកចេញពីផ្ទះរបស់អ្នក នោះអ្នកធ្វើការសង្គមកិច្ច មានពេល **2 ថ្ងៃធ្វើការពេញ** ដើម្បីសំរេចបើសិនកូនរបស់អ្នកអាចនៅជាមួយអ្នក ដោយសុវត្ថិភាព។ បើអ្នកធ្វើការសង្គមកិច្ច គិតថាកូនរបស់អ្នក**គ្មាន**សុវត្ថិភាព នៅជាមួយអ្នកទេ គេនឹង:
   - យក*ញត្តិ* មួយទៅតុលាការពិសេសសំរាប់ក្មេង (តុលាការយុវជន), និង
   - ស្នើតុលាការ ឲ្យទទួលបន្ទុកនៃការថែទាំ ការគ្រប់គ្រង និងការមើលខុសត្រូវ នូវកូនរបស់អ្នក។

   ***សារៈសំខាន់!*** ត្រូវអាន*ញត្តិ*។ វាចុះរាយមូលហេតុទាំងឡាយ *(ការចោទប្រកាន់)* ដែលកូនរបស់អ្នកគ្មានសុវត្ថិភាពនៅក្នុងផ្ទះរបស់អ្នក។ បើអ្នកមិនយល់វាទេ ត្រូវសួរមេធាវីរបស់អ្នក។
2. តុលាការមានពេល **1 ថ្ងៃធ្វើការពេញ** ដើម្បីធ្វើ**សវនាការនៃការឃាត់ឃាំង**។ សវនាការនេះនឹងសំរេច:
   - ដើម្បីប្រគល់ក្មេងឲ្យអ្នកវិញភ្លាមៗ, ឬ
   - ទីកន្លែងសំរាប់ឲ្យក្មេងនឹងស្នាក់នៅសំរាប់ឥឡូវនេះ និងរបៀបដែលអ្នកអាចសួរសុខទុក្ខក្មេង។
3. សវនាការជាបន្ទាប់មកទៀត នឹងធ្វើឡើងក្នុងពេល **15 ថ្ងៃធ្វើការ** លុះត្រាតែចៅក្រមសំរេចថាត្រូវការពេលថែមទៀត។ គេបានហៅវាថា **សវនាការយុត្តាធិការ**។ នោះគឺជាពេលដែលចៅក្រមនឹងមើលស្ថានការណ៍របស់ក្មេងយ៉ាងជិតដល់ និងសំរេចបើសិនមានការចោទប្រកាន់អ្វីមួយនៅក្នុង*ញត្តិ* គឺពិតប្រាកដ។
   - បើចៅក្រមសំរេចថាគ្មានណាមួយដែលពិតប្រាកដទេ កូនរបស់អ្នកនឹងបានប្រគល់ឲ្យអ្នកវិញ។
   - បើចៅក្រមជឿថាការចោទប្រកាន់គឺពិតប្រាកដ កូនរបស់អ្នកអាច នឹងក្លាយជា**មនុស្សក្នុងបន្ទុករបស់តុលាការ**។

## បើកូនរបស់អ្នកក្លាយជាមនុស្សក្នុងបន្ទុករបស់តុលាការ

វានឹងមានសវនាការមួយទៀត (ហៅថា **សវនាការផ្ទេរសិទ្ធិ**) នៅពេលនោះចៅក្រមនឹងសំរេច:

- ទីកន្លែងដែលកូនរបស់អ្នកគួរតែរស់នៅ,
- ពេលវេលា ទីកន្លែង និងរបៀបអ្នកអាចសួរសុខទុក្ខកូនរបស់អ្នក, និង
- អ្វីខ្លះត្រូវតែបានធ្វើ ដើម្បីដោះស្រាយបញ្ហាដែលបានបណ្តាលឲ្យកូនរបស់អ្នក ត្រូវបានយកចេញពីផ្ទះរបស់អ្នក។ (នេះគឺហៅថា *គំរោងការជួបជុំគ្នាវិញ*)។

សវនាការនេះនឹងធ្វើនៅពេលព្រមគ្នានឹងសវនាការយុត្តាធិការ។ បើសិនអ្នក ឬកូនរបស់អ្នកមិនយល់ស្របជាមួយនឹងការសំរេចរបស់ចៅក្រម អ្នកអាចនឹងសូមឲ្យសាលាឧទ្ធរណ៍ពិនិត្យមើលឡើងវិញ នូវការសំរេចរបស់ចៅក្រម។

**តើមានសំណួរឬទេ?** សូមពិគ្រោះជាមួយមេធាវីរបស់អ្នក និងស្វែងយល់ថែមទៀត អំពីករណីដូចនឹងករណីរបស់អ្នកនៅឯ:
**courts.ca.gov/selfhelp-childabuse**